អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងថវិកាកែសម្រួលថ្មីសម្រាប់ឆ្នាំ ២០១២-២០១៣ របស់ អ.វ.ត.ក ត្រូវបានអនុម័ត

គម្រោងថវិកាកែសម្រួលថ្មីសម្រាប់ឆ្នាំ ២០១២-១៣ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានអនុម័តដោយក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ហើយក៏បានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ អ.វ.ត.ក រួចហើយ។

ក្នុងគម្រោងថវិកាកែសម្រួលនេះ អ.វ.ត.ក បានកាត់បន្ថយថវិកាសម្រាប់ឆ្នាំ ២០១២-១៣ ចំនួន ១៥,១ លាន ដុល្លារអាមេរិក ហើយថវិកាសរុបនៅក្នុងគម្រោងដែលបានកែសម្រួលរួចហើយ គឺ ៦៩,៦ លាន ដុល្លារអាមេរិក (តួលេខនេះមិនរួមបញ្ចូលកញ្ចប់ថវិកាសម្រាប់ករណីបន្ទាន់នោះទេ) និងត្រូវបានបែងចែកដូចខាងក្រោម៖

| | ២០១២ | ២០១៣ |
|---|---|---|
| ភាគីជាតិ | US$ ៩.២៤០.៥០០ | US$ ៩.៣៧០.៣០០ |
| ភាគីអន្តរជាតិ | US$ ២៥.០១១.៧០០ | US$ ២៦.០០៥.១០០ |
| **សរុប** | **US$ ៣៤.២៥២.២០០** | **US$ ៣៥.៣៧៥.៤០០** |

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អ.វ.ត.ក បានថ្លែងថា៖ "ខ្ញុំសូមស្វាគមន៍ចំពោះការអនុម័តលើគម្រោងថវិកាកែសម្រួលថ្មី និងទទួចដល់សហគមន៍ម្ចាស់ជំនួយអន្តរជាតិ ឲ្យផ្តល់ជំនួយជាចាំបាច់ដល់ អ.វ.ត.ក ដោយសារភាគីជាតិនៃ អ.វ.ត.ក មិនទទួលបានការសន្យាផ្តល់ជំនួយថវិកាថ្មីណាមួយនៅឡើយទេ សម្រាប់ឆ្នាំ២០១៣"។

ព័ត៌មានពិស្តារអំពីគម្រោងថវិការបស់ អ.វ.ត.ក អាចរកបាននៅ៖
http://www.eccc.gov.kh/en/about-eccc/finances

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh